យើងទៅរកសេរីភាព។ វាមិនមែនជាមធ្យោបាយដែលគ្មានការឈឺចាប់ទេ ប៉ុន្តែ *"ដ្បិតអ្នកណាដែលបានរងទុក្ខក្នុងសាច់ឈាម នោះបានឈប់ខាងឯអំពើបាបហើយ"* (១ពេត្រុស 4:1)។ យើងអាចឈានដល់ចំណុចមួយ ដែលយើងស្អប់កិច្ចការខាងសាច់ឈាមរបស់ខ្លួនយ៉ាងខ្លាំង រហូតដល់វាមិនអាចល្បួងយើងឲ្យប្រព្រឹត្តអំពើបាបបានទៀតឡើយ។

ទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវ

នៅក្នុង ចម្បាំងគ្រប់សម័យកាល ដែលអ្នក និងខ្ញុំកំពុងចូលរួម ពួកជំនុំដ៏ពិតគឺជាបន្ទាយការពារដ៏រឹងមាំដែលការពារពិភពលោកពី អាទទឹងនឹងព្រះគ្រីស្ទ។ ប៉ុន្តែ នៅពេលដែលពួកជំនុំក្លែងក្លាយ ធ្លាក់ចេញពីសេចក្តីពិត នៅពេលដែលវាចុះចាញ់នឹងការបោកបញ្ឆោតរបស់សាតាំង និងបោះបង់ភាពស្មោះត្រង់ចំពោះព្រះ បន្ទាយការពារនោះនឹងដួលរលំ ដោយបើកផ្លូវឲ្យ អាទទឹងនឹងព្រះគ្រីស្ទ ត្រូវបានបង្ហាញចេញមក។

ការប្រឆាំងនឹងកើនឡើង ប៉ុន្តែ អ្នកដែលស៊ូទ្រាំដរាបដល់ចុងបញ្ចប់នោះនឹងត្រូវបានសង្គ្រោះ។ ព្រះនឹងប្រើសកម្មភាពអាក្រក់របស់អាទទឹងនឹងព្រះគ្រីស្ទ ដើម្បីចម្រាញ់ពួកជំនុំពិត ឲ្យក្លាយជាកូនក្រមុំដ៏បរិសុទ្ធសម្រាប់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ការក្លាយជាកម្មសិទ្ធិរបស់ពួកជំនុំពិតប្រាកដ៏ មិនមែនអាស្រ័យលើថា យើងជាអ្នកថ្លែងទំនាយ ឬមានអំណោយ ទាននិយាយភាសាដទៃ ឬចងចាំអត្ថបទព្រះគម្ពីរបានប៉ុន្មានខនោះទេ។ ប៉ុន្តែ អ្វីដែលសំខាន់គឺទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងជាមួយព្រះយេស៊ូវគ្រីស្ទ។ តើទ្រង់ពិតជាព្រះអម្ចាស់នៃជីវិតយើងឬទេ? តើយើងបានថ្វាយខ្លួនទាំងស្រុងដល់ទ្រង់ហើយឬនៅ? យើងបង្ហាញថា យើងជាសមាជិកនៃពួកជំនុំពិត នៅពេលយើងគោរព និងបម្រើព្រះអម្ចាស់ដោយឈរយ៉ាងរឹងមាំខាងទ្រង់ទោះបីជាត្រូវប្រឈមមុខនឹងការប្រឆាំង និងការបៀតបៀនក៏ដោយ។ យើងត្រូវតែដាក់ស្លាកសញ្ញានិកាយផ្សេងៗមួយឡែកសិន ហើយសួរខ្លួនឯងថា តើយើងនឹងនៅតែស្មោះត្រង់ចំពោះព្រះយេស៊ូវដែរឬទេ ។

យើងត្រូវតែតស៊ូនឹងអារក្ស ប្រែចិត្តពីអំពើបាបរបស់យើង ហើយចុះចូលចំពោះព្រះ ដើម្បីរារាំងអំណាចគ្រប់គ្រងរបស់សាតាំង។ ប្រសិនបើយើងស្រឡាញ់សេចក្តីពិត ព្រះនឹងការពារយើងពីការបោកបញ្ឆោតទាំងនោះ។

ការអធិស្ឋានបញ្ចប់

ប្រសិនបើអ្នកមានបំណងប្រាថ្នាចង់រួចផុតពីការបោកបញ្ឆោត និងចង់ទទួលជ័យជម្នះក្នុង ចម្បាំងគ្រប់សម័យកាល សូមអធិស្ឋានសេចក្តីអធិស្ឋាននេះជាមួយខ្ញុំឥឡូវនេះ៖

ឱព្រះអម្ចាស់អើយ! យើងខ្ញុំសូមថ្វាយខ្លួនទាំងស្រុងដល់ទ្រង់។ យើងខ្ញុំបដិសេធគ្រប់ផ្នែកទាំងអស់ដែលការបោកបញ្ឆោតអាចមានឥទ្ធិពលនៅក្នុងជីវិតរបស់យើងខ្ញុំ។ យើងខ្ញុំប្រឆាំងនឹងវា ហើយ បណ្តេញវាចេញពីយើងខ្ញុំ សូមរំដោះយើងខ្ញុំឲ្យរួចពីការកាន់កាប់របស់វា ដោយនូវក្នុងព្រះនាមព្រះយេស៊ូវ។

យើងខ្ញុំសូមទទួលយកសេចក្តីពិត ដែលជាព្រះយេស៊ូវ សេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរ និងសេចក្តីពិតដែលមកពីព្រះវិញ្ញាណបរិសុទ្ធ។ យើងខ្ញុំបើកចិត្ត និងគំនិតរបស់យើងខ្ញុំនៅចំពោះទ្រង់ សូមឲ្យទ្រង់បំពេញយើងខ្ញុំដោយសេចក្តីពិតរបស់ទ្រង់។ ទូលបង្គំអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សេចក្តីបង្រៀនជាលិខិតរបស់លោកដេរេក ព្រីនស៍ អាចទាញយកដោយឥតគិតថ្លៃពីគេហទំព័ររបស់យើង www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

ISSUE #094

លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត

ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY

ចម្បាំងគ្រប់សម័យកាល

ផ្នែកទី ៣៖ការយកឈ្នះលើចម្បាំងគ្រប់សម័យកាល

នៅក្នុងការកែសម្រួលថ្មីនៃសៀវភៅ ការការពារពីការបោកបញ្ឆោត ដែលឥឡូវនេះត្រូវបានចេញផ្សាយក្រោមចំណងជើងថ្មីថា ចម្បាំងគ្រប់សម័យកាល លោក ដេរេក ព្រីនស៍ បានព្រមានអំពីគ្រោះថ្នាក់ដ៏ធំបំផុតដែលគ្រីស្ទបរិស័ទនឹងត្រូវប្រឈមមុខនៅគ្រាចុងក្រោយនេះគឺ ការបោកបញ្ឆោត ។

ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ ប៉ុន្តែ សាតាំងតែងតែមានយុទ្ធសាស្ត្រដើម្បីរំខានដល់គោលបំណងរបស់ព្រះ។ ដើម្បីទប់ទល់នឹងវា យើងត្រូវយល់អំពីគោលដៅរបស់វាសម្រាប់គ្រាចុងក្រោយនេះ។ នេះគឺជាចំណុចផ្តោតសំខាន់នៃផ្នែកទីបីនៃចម្បាំងគ្រប់សម័យកាល។

ការអត់ការផ្តោតអារម្មណ៍

ខ្ញុំបានជួបគ្រីស្ទបរិស័ទជាច្រើនដែលងាយរងការ វិខាន និងបាត់បង់ការផ្តោតអារម្មណ៍លើព្រះជាម្ចាស់។ មានវិធីរាប់មិនអស់ដែលអារក្សអាចប្រើដើម្បីបង្វែរយើងឲ្យឆ្ងាយ ពីគោលបំណងរបស់ព្រះសម្រាប់ជីវិតយើង។ ដោយវិធីណាក៏ដោយឲ្យតែមានប្រសិទ្ធភាព សាតាំងនឹងនាំយើងឲ្យចេញពីផ្លូវនៃបំណងព្រះហឫទ័យរបស់ព្រះ។ មនុស្សម្នាក់ប្រហែលជាមិនបាត់បង់សេចក្តីសង្គ្រោះទេ ប៉ុន្តែគាត់អាចទទួលរង្វាន់ក្នុងសិរីល្អ តិចជាងអ្វីដែលគាត់អាចទទួលបាន។ លោកប៉ុល បានសរសេរទៅកាន់ក្រុមជំនុំនៅក្រុងភីលីព អំពីការបញ្ចប់ដំណើររបស់គាត់ និងការសម្រេចគោលដៅដែលព្រះជាម្ចាស់បានត្រាស់ហៅគាត់ឲ្យធ្វើ៖

មិនមែនថា ខ្ញុំបានទទួល ឬថា ខ្ញុំបានគ្រប់លក្ខណ៍ហើយនោះទេ តែខ្ញុំកំពុងតែដេញតាម សង្ឃឹមនឹងចាប់ឲ្យបានសេចក្តី ដែលព្រះគ្រីស្ទយេស៊ូវបានចាប់ខ្ញុំឲ្យបាននោះដែរ, បងប្អូនអើយ ខ្ញុំមិនរាប់ថាខ្លួនខ្ញុំចាប់បានហើយនោះទេ តែមានសេចក្តីនេះ១ គឺថា ខ្ញុំភ្លេចសេចក្តីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅឯសេចក្តីខាងមុខទៀត។ (ភីលីព 3:12–13)

ខ្ញុំបានសិក្សាព្រះគម្ពីរយ៉ាងស៊ីជម្រៅ អំពីតម្រូវការសម្រាប់ការបំពេញការត្រាស់ហៅរបស់យើងក្នុងព្រះគ្រីស្ទ ហើយខ្ញុំជឿថា វាអាចសង្ខេបបានដោយពាក្យតែមួយគឺ "ចិត្តគំនិតតែមួយ" ។ ប្រសិនបើអ្នកមានចិត្តពីរ ហើយអនុញ្ញាតឲ្យគំនិតរបស់អ្នកត្រូវបានបង្វែរ នោះអ្នកនឹងមិនអាចបំពេញការត្រាស់ហៅរបស់អ្នកបានឡើយ។

មុរសគមខ្ចប

នៅកណ្តាលទសវត្សរ៍ឆ្នាំ 1950 ខ្ញុំកំពុងបម្រើការជាគ្រូគង្វាលនៃពួកជំនុំ ពេនទីកូស្ត នៅកណ្តាលទីក្រុងឡុង។ បីដងក្នុងមួយសប្តាហ៍ យើងធ្វើការប្រជុំផ្សាយដំណឹងល្អតាមដងផ្លូវ នៅកន្លែងមួយហៅថា ជ្រុងអ្នកនិយាយ ម៉ាបល អាក (Speaker's Corner, Marble Arch)។

ក្នុងអំឡុងពេលនោះ ខ្ញុំបានសុបិនឃើញរូបភាពយ៉ាងច្បាស់មួយ។ ខ្ញុំឃើញការប្រជុំតាមដងផ្លូវមួយដែលមានមនុស្សឈរជារង្វង់ស្តាប់បុរសម្នាក់កំពុងអធិប្បាយដោយក្តីភ្លៀវភ្លា។ ប៉ុន្តែពេលខ្ញុំមើលគាត់ ខ្ញុំមិនចូលចិត្តអ្វីដែលខ្ញុំឃើញទេ។ គាត់មានរូបរាងខ្វេរជើងម្ខាងពិការ ហើយមានខ្នងគម។ ខ្ញុំបាននិយាយក្នុងចិត្តថា "អ្វីដែលគាត់កំពុងនិយាយគឺល្អ ប៉ុន្តែ ខ្ញុំមិនចូលចិត្តរូបរាងគាត់បែបនោះទេ" ។

ពេលខ្ញុំភ្ញាក់ពីដំណេក ខ្ញុំមិនបានយកចិត្តទុកដាក់ចំពោះវាឡើយ រហូតដល់វាកើតឡើងម្តងទៀតបន្ទាប់ពីពីរសប្តាហ៍ក្រោយមក។ រឿងនេះធ្វើឲ្យខ្ញុំយល់ថា ព្រះជាម្ចាស់កំពុងព្យាយាមប្រាប់ខ្ញុំពីរឿងអ្វីមួយ។ ខ្ញុំបានចាប់ផ្តើមអធិស្ឋាន រៀបរាប់អំពីសាច់រឿងនោះទៅកាន់ព្រះអម្ចាស់ ហើយសុំឲ្យទ្រង់បង្ហាញពីអ្នកអធិប្បាយនោះ។ តើមនុស្សនោះ គឺជានរណា? សំនួរនេះត្រូវបានឆ្លើយតបក្នុងរបៀបដូចគ្នាដែលហោរា ណាថាន់ បានឆ្លើយដល់ស្តេចដាវីឌ៖ *"ឯមនុស្សនោះ គឺជាអង្គទ្រង់នេះហើយ..."* (២សាំយ៊ូអែល 12:7) ។

ឈើឆ្កាង៖ ជាមធ្យោបាយសង្គ្រោះយើង

ខ្ញុំបានយល់ថា ព្រះមិនមែនកំពុងវាយតម្លៃលើការអធិប្បាយរបស់ខ្ញុំទេ ប៉ុន្តែ ទ្រង់កំពុងមើលខ្ញុំ ហើយទ្រង់មិនពេញចិត្តនឹងអ្វីដែលទ្រង់បានឃើញឡើយ។ នៅពេលនោះ ខ្ញុំបានទទួលសេចក្តីសង្គ្រោះ បានទទួលបុណ្យជ្រមុជទឹក បានជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ ហើយទទួលអំណោយទានក្នុងការនិយាយភាសាដទៃ។ វាគឺក្នុងរដូវកាលនៃពិធីបុណ្យព្រះអង្គមានព្រះជនរស់ (បុណ្យអេសធើរ) ពេលនោះហើយរូបភាពនៃឈើឆ្កាងបី នៅលើកំពូលភ្នំលលាក្បាល (Golgotha) បានលេចឡើងច្បាស់លាស់នៅក្នុងចិត្តខ្ញុំ។ ឈើឆ្កាងនៅកណ្តាលខ្ពស់ជាងឈើឆ្កាងពីរផ្សេងទៀត។

ពេលខ្ញុំពិចារណារូបភាពនេះក្នុងចិត្ត ខ្ញុំមានអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធកំពុងមានបន្ទូលមកកាន់ខ្ញុំដោយមានបន្ទូលអំពី៖ "ឈើឆ្កាងនៅចំកណ្តាលនោះ តើវាត្រូវបានធ្វើឡើងសម្រាប់នរណា?" បន្ទាប់មកទ្រង់មានបន្ទូលថា៖ "សូមប្រុងប្រយ័ត្នមុនពេលអ្នកឆ្លើយ" ខ្ញុំបានគិតមួយសន្ទុះ បន្ទាប់មកឆ្លើយថា៖ "វាត្រូវបានធ្វើឡើងសម្រាប់បាវ៉ាបាស" ។ ទ្រង់បានមានបន្ទូលថា៖ "ត្រឹមត្រូវហើយ" ។

ភ្លាមនោះ ខ្ញុំបានដឹងអ្វីមួយដែលខ្ញុំមិនធ្លាប់គិតពីមុនមក។ ឈើឆ្កាងគឺសម្រាប់ បាវ៉ាបាស វាកំពុងរង់ចាំគាត់។ ប៉ុន្តែ នៅវិនាទីចុងក្រោយ ព្រះវិញ្ញាណបរិសុទ្ធបានរំឭកខ្ញុំថា ព្រះយេស៊ូវ បានយាងមកជំនួសកន្លែងរបស់បាវ៉ាបាស ។ "បាទ" ខ្ញុំសូមអះអាងថានោះជាការពិត។

បន្ទាប់មក ខ្ញុំក៏បានដឹងថា ខ្ញុំគឺជាឧក្រិដ្ឋជនដែលឈើឆ្កាងនោះត្រូវបានរៀបចំសម្រាប់។ វាត្រូវបានធ្វើឡើងតាមទំហំរបស់ខ្ញុំ។ វាត្រូវបានបញ្ជូរនៅទីតាំង ដែលខ្ញុំសមនឹងត្រូវព្យួរ។ មនុស្សចាស់របស់ខ្ញុំមិនមានអ្វីសាកសមក្រៅពីឈើឆ្កាងនេះទេ ប៉ុន្តែ ព្រះយេស៊ូវ បានយាងមកជំនួសកន្លែងរបស់ខ្ញុំ។ មនុស្សចាស់របស់ខ្ញុំត្រូវបានឆ្កាងក្នុងទ្រង់។

ការឆ្ពោះតម្រង់ទៅមុខ

ខ្ញុំមិនទាន់ក្លាយជាអ្នកដែលល្អឥតខ្ចោះទេ ប៉ុន្តែ ខ្ញុំកំពុងឆ្ពោះតម្រង់ទៅខាងមុខ រកគោលដៅចុងក្រោយបំផុត។ ខ្ញុំមិនឈប់នៅមួយកន្លែង ឬជាប់នៅក្នុងទម្លាប់ចាស់ៗទេ។ ខ្ញុំមិនយកចិត្តទុកដាក់នឹងអ្វីដែលលោកីយ៍និយាយ ឬគិតអំពីខ្ញុំទេ ។ អ្វីដែលសំខាន់សម្រាប់ខ្ញុំ គឺអំពីព្រះដំរិះរបស់ព្រះជាម្ចាស់។ ខ្ញុំត្រូវបានរំដោះចេញពីទាសកររនៃការគិតរបស់លោកីយ៍នេះហើយ។

លោកប៉ុល បាននិយាពីសារដ៏សំខាន់នេះថា៖ *"ដោយសារទ្រង់ នោះលោកីយ៍បានត្រូវជាប់ឆ្កាងខាងឯខ្ញុំ ហើយខ្ញុំខាងឯលោកីយ៍ដែរ"* (កាឡាទី 6:14)។ ក្នុងពាក្យផ្សេងទៀត ពេលលោកីយ៍មើលទៅកាន់លោកប៉ុល អ្វីដែលពួកគេមើលឃើញគឺជាសាកសពមួយ ដែលបានជាប់លើឈើឆ្កាងប៉ុណ្ណោះ។ ហើយនៅពេលលោកប៉ុល មើលទៅលោកីយ៍វិញ គាត់ក៏បានឃើញអ្វីដូចគ្នា គឺសាកសពមួយដែលបានជាប់នៅលើឈើឆ្កាង។ នោះគឺជាតម្លៃដែលលោកិយមានចំពោះគាត់។ ទ្រព្យសម្បត្តិ ចំណេះដឹង ឬអំណាចរបស់លោកិយ មិនបានធ្វើឲ្យគាត់ចាប់អារម្មណ៍ឡើយ ព្រោះរបស់ទាំងអស់នោះកំពុងតែកន្លងបាត់ទៅ។

សូមអរព្រះគុណព្រះសម្រាប់ឈើឆ្កាង! ប្រសិនបើគ្មានឈើឆ្កាងទេ យើងនឹងក្លាយជាទាសកររៀងរហូត។ ឈើឆ្កាង គឺជាមធ្យោបាយរបស់

